multicultural health communication

Khmer
[DOH-7100]

# បូសទ្រនិច និង ពងបែករលាក

## Boils and Impetigo

**តើបូសទ្រនិចជាអ្វី ?**

បូសទ្រនិចជារោគឆ្លងនៅលើស្បែកមនុស្ស ។ ជាទូទៅបណ្តាលមកពីបាក់តេរីឈ្មោះ ស្តាហ្វីឡូកូកីស (Staphylococcus)។ បូសទ្រនិចមានលក្ខណៈទន់, ហើមឈឺ, ហើយពោរពេញដោយខ្ទុះ។ ជាទូទៅ ភាពពកទន់នេះបាត់ទៅវិញ នៅពេលបូសទ្រនិចនោះបែកធ្លាយខ្ទុះនិងទឹករងៃចេញអស់ ។

**តើពងបែករលាកជាអ្វី ?**

ពងបែករលាកជារោគឆ្លងនៅលើស្បែកបណ្តាលមកពីបាក់តេរី ស្តាហ្វីឡូកូកីស (Staphylococcus) ឬ ស្រ្តេបហ្វីឡូកូកីស (StrephylococcuS) ។ រោគសញ្ញានៃពងបែករលាក អាចជាដំកន្ទួលតូចៗ ឬបន្ទះដែលមានក្រមរពណ៌ក្រមៅ។ ជួនកាលគេហៅពងបែករលាកនេះ ថា “ពងបែកនៅសាលា (School sore)” ។

**តើគេព្យាបាលបូសទ្រនិច និងពងបែករលាក យ៉ាងដូចម្តេច ?**

ប្រសិនបើលោកអ្នកមានរោគសញ្ញានៃបូសទ្រនិច ឬ ពងបែករលាក:

- ទៅជួបវេជ្ជបណ្ឌិតដើម្បីទទួលដំបូន្មានក្នុងការព្យាបាលជម្ងឺទាំងពីរនេះ
- បើសិនជាពងបែករលាកទាំងនោះតូចៗ ឬ តិចតួច ការប្រើក្រែមសំលាប់មេរោគនៅនឹងកន្លែង គួបផ្សំនិងការរុំដោយក្រណាត់សំពត់ក្តៅអាចជួយបាន។
- វេជ្ជបណ្ឌិតរបស់លោកអ្នកអាចចេញវេជ្ជបញ្ជាឲ្យប្រើថ្នាំគ្រាប់អង់ទីប៊ីយ៉ូទិកឬថ្នាំលាបលើស្បែក។ ការប្រើអង់ទីប៊ីយ៉ូទិក ឲ្យគ្រប់ក៏រិតថ្ងៃមានសារសំខាន់ ។ បើអ្នកមិនធ្វើតាមទេ បែកអាចកើតឡើងវិញបាន។

**តើបូសទ្រនិច និងពងបែករលាក ឆ្លងរាលដាលយ៉ាងដូចម្តេច ?**

បូសទ្រនិចនិងពងបែករលាក ឆ្លងរាលដាលពីមនុស្សម្នាក់ទៅមនុស្សម្នាក់តាមរយៈ ៖

- ការប៉ះ ឬ ញ៉ិចបូសទ្រនិច ឬ ពងបែករលាកនោះ
- ប្រើកន្សែងដែលមានប្រឡាក់មេរោគ, សំលៀកបំពាក់ឬ កំរាលពូកប្រើដោយមនុស្សដែលកើតបូសទ្រនិច ឬ ពងបែករលាក។
- ប្រើប្រាស់គ្រឿងសំអិតសំអាង (ឧទាហរណ៍ កន្ត្រៃកាត់ក្រចក, ចន្លាស/តម្បៀត, ប្រដាប់កោរពុកមាត់) ប្រើដោយអ្នកដែលកើតបូសទ្រនិច ឬ ពងបែករលាក។

**តើអ្នកអាចបញ្ឈប់ការឆ្លងរាលដាលនៃបូសទ្រនិច និងពងបែករលាក យ៉ាងដូចម្តេច?**



NSW GOVERNMENT | Health

**លាងដៃរបស់អ្នក**

ការលាងដៃជាមធ្យោបាយដ៏មានសារសំខាន់បំផុតដើម្បីរាំងរាការឆ្លងរាលដាលនៃបូសទ្រនិចនិងពងបែករលោក។ សូមលាងដៃទាំងមូលឲ្យបានគ្រប់ផ្នែកទាំងអស់ (រួមទាំងចន្លោះម្រាមដៃនិងក្រោមក្រចក) ឲ្យបានហ្មត់ចត់ជាមួយសាប៊ូ និងទឹកម៉ាស៊ីនឲ្យបាន ១០ - ១៥ វិនាទី ។ លាងឲ្យបានល្អ និង ជូតឲ្យស្ងួត (ដោយក្រដាសអនាម័យបើសិនអ្នកមាន) ។ លាងដៃរបស់អ្នក ៖

- មុននឹងក្រោយពីប៉ះកាន់ ឬ លាបរុំកន្លែងដែលក្លាយ ឬ របួស
- ក្រោយចេញពីបង្គន់
- ក្រោយញើសសំបោរ
- មុនរៀបចំ ឬ បរិភោគអាហារ
- មុនកាន់ទារកទើបកើត
- ក្រោយប៉ះ ឬ កាន់សំលៀកបំពាក់ ឬ កំរាលពូក ឬ ស្រោមខ្នើយមិនទាន់បោកគក់
- ក្រោយកាន់សត្វពាហនៈ ឬ លាមកវា

**រុំបូសទ្រនិច និង ពងបែករលោក**

- រុំឬគ្របបូសទ្រនិចនិងពងបែករលោក ដោយក្រណាត់មិនជ្រាបទឹកនៅពេលថ្ងៃ
- ក្មេងដែលមានចេញពងបែករលោក មិនគួរទៅសាលារៀន ឬ ទារកដ្ឋានទេរហូតដល់ក្រោយពេលដែលពួកគេបាន ទទួលការព្យាបាលពេញមួយថ្ងៃ

**មិនត្រូវប្រើប្រាស់រួមគ្នានូវ:**

- កន្សែង, សំលៀកបំពាក់ ឬកំរាលពូកប្រឡាក់ឡើយ។ បើសិនអ្នកដេករួមគ្រែជាមួយនរណាម្នាក់ត្រូវរុំពងបែក ឬ ដំបៅពេញមួយយប់តែម្តង ។
- គ្រឿងសំភារៈសំអិតសំអាងមួយចំនួន មានដូចជា : កន្ត្រៃកាត់ក្រចក, ចន្ទាស/តម្បៀត, ប្រដាប់កោរ និង ច្រាស់ដុសធ្មេញ ។ ចំពោះព័ត៌មានបន្ថែមសូមទាក់ទងមន្ទីរសុខភាពសាធារណៈនៅមូលដ្ឋានរបស់អ្នក, មណ្ឌលសុខភាព សហគមន៍ ឬ វេជ្ជបណ្ឌិត ។

## ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW



**1300 066 055**

**www.health.nsw.gov.au**